ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខ: ៣២/០១២៥.ប.ស្ត

# សេចក្តីណែនាំ

# ស្តីពី

# ការអនុវត្តយុទ្ធនាការសម្អាតផ្លូវជាតិ «ផ្លូវជាតិគ្មានសំរាមប្លាស្ទិក»

ក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ យុទ្ធសាស្ត្រនេះបានតម្រង់ទិសនិងចង្អុលបង្ហាញពីការងារអាទិភាព ការលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការការពារធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព ជាមួយនឹងសសរស្តម្ភចំនួន ៣ (បី) គឺ «**ភាពស្អាត ភាពបៃតង និងចីរភាព**» ដែលជាការចូលរួមចំណែកក្នុងវិស័យបរិស្ថាន ការលើកកម្ពស់សោភ័ណភាព បរិស្ថាន អនាម័យ សុខភាពសាធារណៈ និងការចូលរួមចំណែកក្នុងការអភិវឌ្ឍមាតុភូមិឱ្យកាន់តែរីកចម្រើនជឿនលឿនទៅមុខជានិច្ចនិរន្តរ៍។

ដើម្បីភាពស្អាតនៅកម្ពុជា ក្រសួងបរិស្ថានបានដាក់ចេញនូវយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកជាជំហានៗ ក្នុងនោះយុទ្ធនាការទី១ ក្រោមប្រធានបទ «**ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ**» បានចាប់ផ្តើមពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ដោយបានបង្ហាញពីការប្តេជ្ញាចិត្តចូលរួមដើម្បីកម្ពុជាស្អាត គ្មានការបំពុលដោយសំណល់ប្លាស្ទិក និងយុទ្ធនាការទី២ គឺ «**កម្ពុជាស្អាត ខ្មែរធ្វើបាន**» បានចាប់ផ្តើមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ ដែលជាសកម្មភាពសម្អាត និងប្រមូលសំរាម និងសំណល់ប្លាស្ទិកនៅតាមបរិវេណលំនៅឋាន សហគមន៍ សាលារៀន វត្តអារាម និងទីសាធារណៈនានា។ យុទ្ធនាការទាំងពីរនេះ ទទួលបានការគាំទ្រនិងជោគជ័យជាបន្តបន្ទាប់ ដោយមានកិច្ចសហការល្អពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ កម្មករ-កម្មការនី ព្រះសង្ឃ និងប្រជាពលរដ្ឋទូទាំងប្រទេស។

ក្នុងទិសដៅបន្តសម្អាតកម្ពុជា ក្រសួងបរិស្ថានបានកំណត់យកថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ បើកយុទ្ធនាការជំហានទី៣ គឺ យុទ្ធនាការសម្អាតផ្លូវជាតិ ក្រោមប្រធានបទ «**ផ្លូវជាតិគ្មានសំរាមប្លាស្ទិក**» ក្នុងគោលបំណង ដើម្បីលើកកម្ពស់សោភ័ណភាពទីក្រុង ទីប្រជុំជន នៅតាមបណ្តាផ្លូវជាតិទូទាំងប្រទេសកាន់តែស្រស់ស្អាត មានអនាម័យ និងសណ្តាប់ធ្នាប់ល្អ ដើម្បីជាភាពទាក់ទាញអ្នកវិនិយោគ អ្នកទេសចរណ៍មកប្រទេសកម្ពុជាកាន់តែច្រើនឡើង ជាពិសេស ដើម្បីការរស់នៅប្រកបដោយផាសុខភាព និងភាពស៊ីវិល័យ។

ដើម្បីជំរុញឱ្យយុទ្ធនាការសម្អាតផ្លូវជាតិ ក្រោមប្រធានបទ «**ផ្លូវជាតិគ្មានសំរាមប្លាស្ទិក**» ប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា ក្រសួងបរិស្ថាន សូមស្នើឱ្យមានកិច្ចសហការពីគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ



អគារមរតកតេជោ ដីឡូតិ៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 213 908 / 023 220 369

វិស័យឯកជន សង្គមស៊ីវិល សហគមន៍ ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ និងសាធារណជន ចូលរួមអនុវត្ត ដូចតទៅ៖

**ក. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖**

១-សូមធ្វើការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ជំរុញការចូលរួមក្នុងការធ្វើអនាម័យ។

២-ដឹកនាំ ចាត់ចែងការរៀបចំឱ្យមានការសម្អាតសំរាម និងសំណល់ប្លាស្ទិក នៅតាមបណ្តាតាមដងផ្លូវទាំងអស់ និងនៅតាមមូលដ្ឋានរបស់ខ្លួន ឱ្យបានជាប់ជាប្រចាំ។

៣-ជំរុញការគ្រប់គ្រង ទុកដាក់ និងវេចខ្ចប់សំរាម សំណល់រឹងក្នុងធុងសំរាម ឬនៅតាមទីតាំងកំណត់ឱ្យបានត្រឹមត្រូវ ជៀសវាងការដុត ឬបោះចោលមិនត្រឹមត្រូវ ដែលអាចបង្កការប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងគុណភាពបរិស្ថាន។

៤-ជំរុញការដាំដើមឈើនៅតាមទីសាធារណៈ តាមដងផ្លូវ បង្កើនគម្របបៃតង សោភ័ណភាពទីក្រុងនិងទីប្រជុំជន នៅតាមមូលដ្ឋានរបស់ខ្លួន។

**ខ. ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ មន្ទីរពេទ្យ សាលារៀន វត្តអារាម៖**

១-សូមចូលរួមធ្វើការផ្សព្វផ្សាយនិងបន្តអនុវត្តយុទ្ធនាការ «**ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ**» និងយុទ្ធនាការ «**កម្ពុជាស្អាត ខ្មែរធ្វើបាន**» ដោយបំផុសស្មារតីនិងសកម្មភាពសម្អាតអនាម័យបរិស្ថាន ទុកដាក់សំរាម ព្រមទាំងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក។

២-ចាត់ចែងធ្វើអនាម័យទាំងក្នុង និងក្រៅបរិវេណអង្គភាពរបស់ខ្លួន ធ្វើការគ្រប់គ្រងសំរាម សំណល់រឹង សំណល់រាវ និងសំណល់ប្លាស្ទិកឱ្យបានត្រឹមត្រូវ តាមរយៈការញែក ការទុកដាក់ និងមិនបោះចោលតាមដងផ្លូវ ទីសាធារណៈ ប្រភពទឹកសាធារណៈ ឬដុតនៅទីចំហរ។

៣-ចូលរួមអនុវត្តតាមការណែនាំរបស់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធការគ្រប់ គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិក។

**គ. តំបន់សហគមន៍ កន្លែងកម្សាន្ត រមណីយដ្ឋាន ភោជនីយដ្ឋាន និងអាហារដ្ឋាន៖**

១-ចូលរួមធ្វើអនាម័យ និងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ធ្វើការសម្អាតទីតាំងរបស់ខ្លួនជាប់ប្រចាំ សន្សំសំចៃថាមពល ការពារថែរក្សាជីវៈចម្រុះ និងធនធានធម្មជាតិ។

២-ចូលរួមសកម្មភាពសម្អាតតាមដងផ្លូវ ឬទីសាធារណៈ ក្នុងមូលដ្ឋានរបស់ខ្លួនតាមការដឹកនាំសម្របសម្រួលរបស់អាជ្ញាធរមូលដ្ឋាន និងបន្តការសម្អាតនេះឱ្យបានជាប់ជាប្រចាំនៅក្នុង និងជុំវិញបរិវេណទីតាំងរបស់ខ្លួន។

៣-ត្រូវយកចិត្តទុកដាក់លើការគ្រប់គ្រងសំរាម សំណល់រឹង សំណល់ប្លាស្ទិក និងសំណល់រាវឱ្យបានត្រឹមត្រូវ។

**ឃ. ប្រព័ន្ធផ្សព្វផ្សាយនិងអ្នកសារព័ត៌មានជាតិ អន្តរជាតិ ៖**

សូមចូលរួមផ្សព្វផ្សាយអំពីយុទ្ធនាការបរិស្ថាន គោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពពាក់ព័ន្ធនឹងវិស័យបរិស្ថានឱ្យបានទូលំទូលាយដល់សាធារណជន ដើម្បីបង្កើនការយល់ដឹង និងបំផុសការចូលរួមយុទ្ធនាការឱ្យទទួលបានជោគជ័យដើម្បីលើកកម្ពស់អនាម័យ សោភ័ណភាព បរិស្ថាន និងការអភិវឌ្ឍដោយចីរភាព។

ក្នុងស្មារតីនេះ ក្រសួងបរិស្ថានមានសេចក្តីសង្ឃឹមយ៉ាងមុតមាំ និងសូមអំពាវនាវដល់ក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ វិស័យឯកជន អង្គការសង្គមស៊ីវិល សមាគម ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ សហគមន៍ និងអ្នកពាក់ព័ន្ធ មេត្តាចូលរួមសហការ និងអនុវត្តឱ្យបានជោគជ័យនូវយុទ្ធនាការសម្អាតផ្លូវជាតិ ក្រោមប្រធានបទ «**ផ្លូវជាតិគ្មានសំរាមប្លាស្ទិក**» នេះ។

ថ្ងៃសុក្រ ៥កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួង បរិស្ថាន

**អ៊ាង សុផល្លែត**